# គំនូរស្តីពីសំពត់ខ្មែរត្រូវបានតាំងបង្ហាញ

**លោក សុរីតា**

ភ្នំពេញ ៖ សំពត់ជាសម្លៀកបំពាក់មួយប្រភេទដែលប្រជាជននៅតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសស្ត្រីខ្មែរ តែងតែប្រើប្រាស់ស្លៀកពាក់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន និងនៅក្នុងពិធីការផ្សេងៗ។ វាជាសម្លៀកបំពាក់មួយបែបដែលពេលខ្លះតំណាងឱ្យភាពថ្លៃថ្នូរ និងភាពស្រស់ស្អាត់របស់ស្ត្រី។ ដូច្នេះហើយទើបវិចិត្រសាលបាសាក់បានជ្រើសរើសពិព័រណ៍មួយ ដែលមានឈ្មោះថា"សំពត់ ៖សមុច្ច័យពីភាគតូចៗ" មកដាក់តាំងបង្ហាញនៅក្នុងវិចិត្រសាលរបស់ខ្លួន។

ពិព័រណ៍នេះជាឈុតស្នាដៃសិល្បៈរបស់សិល្បករគំនូរវិចិត្រកម្ម លោក ចាន់ ដានី ដែលបានដកស្រង់យកសំពត់ក្រណាត់រាងចតុកោណកែងដែលទាំងបុរស និងនារីពាក់នៅតំបន់អាស៊ីអាគ្នេយ៍ ដែលសាច់ក្រណាត់មានប្រវត្តិបុរាណ និងមានភាពរស់រវើកនៅក្នុងប្រទេសកម្ពុជា ហើយរហូតមកដល់ពេលបច្ចុប្បន្ននេះ សំពត់ត្រូវបានគេត្បាញដោយដៃ តាមលក្ខណៈប្រពៃណីដោយមានថ្នាំពណ៌ជ្រលក់ធម្មជាតិ និងសូត្រស្តើង ដោយគេប្រើប្រាស់សម្រាប់មុខងារវិចិត្រកម្ម និងពិធីការ ព្រមជាមួយនឹងការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃផងដែរ។

អ្នកនាង ជុំ ចាន់វាសនា អ្នកគ្រប់គ្រងនៅក្នុងវិចិត្រសាលបាសាក់បាននិយាយថា ការដែលវិចិត្រសាលនេះបានសម្រេចចិត្តជ្រើសរើសយកស្នាដៃពិព័រណ៍នេះមកដាក់បង្ហាញដោយសារស្នាដៃរបស់ លោក ចាន់ ដានី បានបង្ហាញពីភាពល្អឯក និងមានលក្ខណៈប្រពៃណីខ្មែរដែលបានបង្កប់នៅខាងក្នុងនោះ។

អ្នកនាងបានបញ្ជាក់ទៀតថា អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺស្នាដៃរបស់វិចិត្រកររូបនេះបានបង្ហាញពីភាពច្នៃប្រឌិតខ្ពស់ក្នុងការយកសម្ភារដែលគេប្រើប្រាស់ប្រចាំថ្ងៃមកបង្កើតជាស្នាដៃសិល្បៈរបស់ខ្លួននេះ។

ចំណែក លោក ចាន់ ដានី សិល្បករដែលបានរៀបចំរូបវិចិត្រកម្មទាំង ១១ផ្ទាំងសម្រាប់ដាក់បង្ហាញនៅក្នុងពិព័រណ៍បាននិយាយថា "ខ្ញុំដាក់បង្ហាញស្នាដៃពិព័រណ៍របស់ខ្ញុំនៅក្នុងវិចិត្រសាល បាសាក់នេះ គឺដើម្បីឱ្យសាធារណជនជាពិសេសអ្នកនិយមវិស័យសិល្បៈឱ្យបានយល់ពីតម្លៃជាសិល្បៈរបស់វត្ថុនីមួយៗ ជាពិសេសតម្លៃជាសិល្បៈរបស់សំពត់របស់ខ្មែរតែម្តង"។

គួររំលឹកថា សិល្បករគំនូរវិចិត្រកម្ម រូបនេះកើតនៅក្នុងឆ្នាំ១៩៨៤ នៅក្នុង ខេត្តព្រៃវែងសព្វថ្ងៃនេះលោករស់នៅ និងធ្វើការនៅភ្នំពេញ។

លោកបានចូលរួមតាំងពិព័រណ៍នៅក្នុងវិចិត្រសាសជាច្រើន នៅក្នុងវិចិត្រសាស "បាសែលសិល្បៈ" នៅក្នុងក្រុង ហុងកុង វិចិត្រសាល១០ Chancery Lane Gallery នៅទីក្រុងបាងកក និងនៅក្នុងវិចិត្រសាសផ្សេងទៀតនៅក្នុងស្រុកផងដែរ។ ■



*រូបគំនូរមួយក្នុងចំណោមរូបគំនូរជាច្រើនទៀតរបស់វិចិត្រករ ចាន់ ដានី ដែលបង្ហាញពីសំពត់ខ្មែរកំពុងដាក់តាំងនៅវិចិត្រសាលបាសាក់ រូបថតលោក សុរិតា*